**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សារលិខិតគាំទ្រ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

*សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវការប្រកាសគាំទ្រជាឱឡារិក និងទាំងស្រុងចំពោះ **ឯកឧត្តម ហ៊ុន ម៉ាណែត** ជាបេក្ខជននាយករដ្ឋមន្ត្រីសម្រាប់បន្តវេនដឹកនាំប្រទេសទៅថ្ងៃអនាគត ស្របតាមការប្រកាសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងនៅព្រឹកថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ នៅក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធនានាក្នុងខេត្តព្រះសីហនុ។

យើងខ្ញុំយល់ឃើញថា **ឯកឧត្តម ហ៊ុន ម៉ាណែត** គឺជាយុវជនជំនាន់ថ្មីមួយរូបដែលពិតជាមានសមត្ថភាពខ្ពស់ មានសីលធម៌ និងគុណធម៌ដ៏ល្អ ជាពិសេស **ឯកឧត្តម ហ៊ុន ម៉ាណែត** បាននិងកំពុងធ្វើសកម្មភាពជាគំរូជាក់ស្តែងជាច្រើនឆ្នាំនៅលើវិស័យសំខាន់ៗជាច្រើនទាំងនៅក្នុងប្រទេស និងលើឆាកអន្តរជាតិដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាជនកម្ពុជា។

តាមរយៈលក្ខណៈសម្បត្តិដ៏ល្អប្រសើរ គួបផ្សំនឹងបទពិសោធន៍ទាំងអស់នេះ ខ្ញុំពិតជាមានជំនឿយ៉ាងមុតមាំថា **«កូនខ្មែរម្នាក់នេះពិតជាអាចធ្វើបានគ្រប់យ៉ាង»** ដើម្បីជំរុញការការពារ និងអភិវឌ្ឍប្រទេសជាតិឱ្យរីកចំរើនជឿនលឿនទៅមុខក្នុងសុខសន្តិភាព និងវិបុលភាព ក៏ដូចជាកសាងកិត្យានុភាពរបស់ជាតិ នៅលើឆាកអន្តរជាតិ។

យើងខ្ញុំសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ៕

ថ្ងៃ សុក្រ ១៣រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ-សុខា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវការប្រកាសគាំទ្រជាឱឡារិក និងទាំងស្រុងចំពោះ **ឯកឧត្តម ហ៊ុន ម៉ាណែត** ជាបេក្ខជននាយករដ្ឋមន្ត្រីសម្រាប់បន្តវេនដឹកនាំប្រទេសទៅថ្ងៃអនាគត ស្របតាមការប្រកាសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងនៅព្រឹកថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ នៅក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធនានាក្នុងខេត្តព្រះសីហនុ។

យើងខ្ញុំយល់ឃើញថា **ឯកឧត្តម ហ៊ុន ម៉ាណែត** គឺជាយុវជនជំនាន់ថ្មីមួយរូបដែលពិតជាមានសមត្ថភាពខ្ពស់ មានសីលធម៌ និងគុណធម៌ដ៏ល្អ ជាពិសេស **ឯកឧត្តម ហ៊ុន ម៉ាណែត** បាននិងកំពុងធ្វើសកម្មភាពជាគំរូជាក់ស្តែងជាច្រើនឆ្នាំនៅលើវិស័យសំខាន់ៗជាច្រើនទាំងនៅក្នុងប្រទេស និងលើឆាកអន្តរជាតិ ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាជនកម្ពុជា។

តាមរយៈលក្ខណៈសម្បត្តិដ៏ល្អប្រសើរ គួបផ្សំនឹងបទពិសោធន៍ទាំងអស់នេះ ខ្ញុំពិតជាមានជំនឿយ៉ាងមុតមាំថា **«កូនខ្មែរម្នាក់នេះពិតជាអាចធ្វើបានគ្រប់យ៉ាង»** ដើម្បីជំរុញការការពារ និងអភិវឌ្ឍប្រទេសជាតិឱ្យរីកចំរើនជឿនលឿនទៅមុខ ក្នុងសុខសន្តិភាព និងវិបុលភាព ក៏ដូចជាកសាងកិត្យានុភាពរបស់ជាតិ នៅលើឆាកអន្តរជាតិ។

ថ្ងៃសុក្រ ១៤ រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០២១